# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
## បានបើកកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំវិធានការគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន







(ភ្នំពេញ) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សា ពីការរៀបចំវិធានការគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលរួមពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនផងដែរដូចជា៖**លោក អ៊ឹង វណ្ណថា** អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, **លោកជំទាវ ឧត្តមសេនីយ៍ឯក ឌុច ដាណា** អគ្គនាយរង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, **ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, **លោកឧត្តមសេនីយ៍ទោ អ៊ិន សារុធ** អនុប្រធាននាយកដ្ឋានកណ្តាលព្រំដែន នៃអគ្គនាយកដ្ឋាននគរបាលជាតិ, **ឯកឧត្តម ឧត្តមសេនីយ៍ទោ យឹម វីរៈ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, **លោកឧត្តមសេនីយ៍ទោ ឆាយ វណ្ណា** ប្រធានាយកដ្ឋានប្រកទ្វារទី១ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ **លោកជំទាវ** មានប្រសាសន៍ទាក់ទងទៅនឹងអំពីបញ្ហាលំបាកមួយចំនួន របស់ពលករដែលទៅធ្វើការនៅប្រទេសថៃ ដូចជា៖ គ្រោះថ្នាក់ចរាចរណ៍ បាញ់សម្លាប់ ឬត្រូវបានសម្លាប់នៅលើទូកនេសាទសមុទ្រ ប្រើប្រាស់ញៀនថ្នាំ ចាញ់បោកថៅកែ និងមេខ្យល់ជាដើម។ ដោយយោងប្រសាសន៍ **សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១២ ធ្នូ ឆ្នាំ ២០១៥ និង **សម្តេចក្រឡាហោម** បានដាក់ចេញនូវវិធានការចំនួន ៦ចំណុច ដោយមានការសហការគ្នាក្នុងការអនុវត្តការងារទៀងទាត់ និងមានប្រសិទ្ធភាព ដើម្បីបង្ការទប់ស្កាត់ ការឆ្លងដែនរបស់ពលករដោយខុសច្បាប់។**លោកជំទាវ**មានប្រសាសន៍បន្តថា សកម្មភាពមេខ្យល់អូសទាញពលករក្នុងស្រុក គឺនៅតែបន្តធ្វើ និងមានចលនាមិនឈប់ឈរក្នុងការ នាំអ្នកថ្មីទៅជំនួសអ្នកចាស់ដែលបាត់បង់កម្លាំងពលកម្ម ថៃត្រូវការតែកម្មករ អ្នកបម្រើតាមផ្ទះ និងភោជនីយដ្ឋានទើបគេយក។




បើយើងខ្វះ ការគ្រប់គ្រងលំហូរពលកររបៀបនេះ យើងនឹងជួបបញ្ហាធំហើយ ថៃនឹងលេងដូចឆ្នាំ២០១៤ ធ្វើឲ្យ

ខាតបង់សេដ្ឋកិច្ចជាតិ ដាច់សង្វាក់ផលិតកម្មរោងចក្រផ្សេងៗ។ យើងនឹងដាក់វិធានការជាក់លាក់មួយ ដើម្បីរិះរកនូវគន្លឹះសំខាន់ៗ ជាវិធានការទប់ស្កាត់ ដើម្បីដោះស្រាយចំពោះពលករអត់ច្បាប់ដែលកំពុងធ្វើការនៅប្រទេសថៃ។

នៅក្នុងកិច្ចប្រជុំពិភាក្សា តំណាងអង្គភាព ស្ថាប័នពាក់ព័ន្ធ បានមានមតិយោបល់ផ្លាស់ប្តូរទៅលើខ្លឹមសារ នៃកិច្ចប្រជុំ ដែលផ្តោតសំខាន់ទៅលើការគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន។ **លោកជំទាវ** បានមានប្រសាសន៍ថា យើងត្រូវធ្វើការ អប់រំផ្សព្វផ្សាយតាមរយៈសារព័ត៌មាន សាលារៀន ឬនៅតាមមូលដ្ឋានជាដើម ចំនែកពលករឆ្លងដែន មិនមែនមានន័យថាបិទច្រករបៀងនោះទេគឺត្រូវដឹងចេញ និងចូលប៉ុន្មាន? មានគម្លាតខុសគ្នាប៉ុន្មាន? គ្រប់គ្រងដោយរបៀបណា? ដើម្បីចេញនូវវិធានការទប់ស្កាត់លើបញ្ហានេះ។




បន្ទាប់មកតំណាងអង្គភាព ស្ថាប័នពាក់ព័ន្ធបានឯកភាពគ្នាដាក់ ចេញនូវវិធានការទប់ស្កាត់លំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែនមួយចំនួនដូចខាងក្រោម៖

-ពន្លឿនសេវាឲ្យបានឆាប់រហ័ស ក្នុងការធ្វើលិខិតឆ្លងដែនជូនពួកគាត់។

-ធ្វើការគ្រប់គ្រងលំហូរពលករឲ្យបានច្បាស់លាស់។

-គ្រប់គ្រងក្រុនហ៊ុន នាំពលករចេញទៅធ្វើការនៅក្រៅប្រទេសឲ្យបានច្បាស់លាស់។

-ឯកភាពការលុបបំបាត់ច្រករបៀង និងមន្ត្រីសមត្ថកិច្ចអនុវត្តឲ្យបានតឹងរ៉ឹងលើការងារនេះ។

**លោកជំទាវ** បានមានប្រសាសន៍បន្តថា យើងត្រូវមានវិធានការបីគឺ **វិធានការអប់រំ, វិធានការច្បាប់** ត្រូវតែធ្វើឲ្យបានជាក់លាក់ និង**វិធានការផ្លាស់ប្តូរ** ចំពោះមន្ត្រីដែលបានឈរជើងយូរមកហើយ និងត្រូវមានការគ្រប់គ្រងលើ ៣ចំណុចគឺ៖ គ្រប់គ្រងក្នុងស្រុក, គ្រប់គ្រងព្រំដែន, គ្រប់គ្រងក្រៅស្រុក។

